00294874

ឯ/ក: D158/2

**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | |
|---|---|
| **សំណុំរឿងលេខ:** | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស |
| **ដាក់ទៅ:** | សហចៅក្រមស៊ើបអង្កេត |
| **ថ្ងៃដាក់:** | ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩ |
| **ភាគីអ្នកដាក់:** | សហមេធាវីរបស់លោក អៀង សារី |
| **ភាសាដើម:** | អង់គ្លេស |
| **ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** | សាធារណៈ: សាធារណៈ |

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27 / 03 / 2009
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CA-Fuy

---

**ញត្តិរបស់លោក អៀង សារី សុំចូលរួម និងទទួលយកតាម**
**សំណើសុំអោយបំពេញកិច្ចស៊ើបសួរទី ១១ របស់ នួន ជា**

---

**អ្នកដាក់ឯកសារ៖**
**សហមេធាវីរបស់លោក អៀង សារី**
លោក អាង ឧត្តម
លោក Michael G. KARNAVAS

**អ្នកទទួលឯកសារ៖**
**សហចៅក្រមស៊ើបអង្កេត**
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Marcel LEMONDE

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 03 / 04 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

00294875

E158/2



លោក **អៀង សារី** តាមរយៈសហមេធាវីការពារក្តីរបស់គាត់ ("មេធាវីការពារក្តី") សូមដាក់ពាក្យសុំចូលរួមជាមួយការដាក់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីរបស់ **នួន ជា** ស្តីពី "សំណើសុំអោយបំពេញកិច្ចស៊ើបសួរលើកទី ១១ " ("សំណើសុំកិច្ចស៊ើបសួរ") ដែលបានស្នើអោយលាតត្រដាងនូវរបាយការណ៍របស់ OIOS និងឯកសារទាក់ទងនានា និងការផ្តួចផ្តើមអោយមានការស៊ើបអង្កេតរដ្ឋបាលទៅលើការចោទប្រកាន់អំពីអំពើពុករលួយនៅតុលាការនេះដែលមិនទាន់បានដោះស្រាយរួច។ ក្នុងការចូលរួមជាមួយសំណើសុំកិច្ចស៊ើបសួរនេះ មេធាវីការពារក្តី សូមទទួលយកដោយឥតលក្ខខណ្ឌនូវអំណះអំណាងផ្លូវច្បាប់ និងអង្គហេតុនានាដែលរៀបចំដោយមេធាវីការពារក្តីរបស់ **នួន ជា** ។ ញត្តិសុំចូលរួមនេះ ត្រូវបានធ្វើឡើងជាការចាំបាច់ដើម្បីជៀសអោយផុតពីភាពអយុត្តិធម៌ជាក់ស្តែង មកលើជនត្រូវចោទទាំងអស់នៅក្នុងសំណុំរឿង ០០២ ដូចដែលមានធ្វើជាក់លាក់នៅក្នុងសំណើសុំនោះ ។ អវត្តមាននៃការលាតត្រដាងបង្ហាញមេធាវីការពារក្តីនូវឯកសារ និងព័ត៌មានដែលបានស្នើសុំ និងតាមរយៈសំណើសុំកិច្ចស៊ើបសួរនេះ ប្រថុយប្រថានអោយមានការបដិសេធសិទ្ធិជនត្រូវចោទ ដើម្បីទទួលបានសវនាការដោយយុត្តិធម៌ដែលសិទ្ធិនេះត្រូវបានគេធានា។ ដំណើរការជំនុំជម្រះក្តីប្រកបដោយតម្លាភាព និងឯករាជ្យ គ្មានការលេចឡើងនូវភាពអយុត្តិធម៌ ឬ ភាពលំអៀង ឬការប្រព្រឹត្តអំពើពុករលួយ គឺជាលក្ខណៈគ្រឹះនៃការគ្រប់គ្រងវិស័យយុត្តិធម៌ដែលត្រឹមត្រូវ។ ហេតុដូច្នេះ ការលាតត្រដាងនូវព័ត៌មាន និងការលាតត្រដាងការបំពេញកិច្ចស៊ើបសួរដោយសហចៅក្រមស៊ើបអង្កេតតាមសំណើសុំរបស់មេធាវីការពារក្តីរបស់ **នួន ជា** គឺមានលក្ខណៈជាសារវ័ន្តដើម្បីធានាសិទ្ធិនានាក្នុងទទួលបានសវនាការដោយយុត្តិធម៌របស់ជនត្រូវចោទទាំងអស់ និងដើម្បីលើកតម្កើងនូវទំនុកចិត្តបន្ថែមទៀតមកលើ **អ.វ.ត.ក** ដែលសព្វថ្ងៃកំពុងខ្វះខាត ដោយសារមានព័ត៌មានលេចលឺជាច្រើនអំពីបញ្ហាពុករលួយដែលមានលក្ខណៈជាការរៀបចំទុក និងជាទូទៅនៅ **អ.វ.ត.ក** ។

សូមលោកសហចៅក្រមទទួលយកសំណើសុំនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២៧** ខែមីនា ឆ្នាំ **២០០៩**

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**